# FORESTS AND LIVELIHOOD ORGANIZATION (FLO)

## សារៈសំខាន់នៃការបង្កើតកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ

Present by :

Mrs. Kann Seyma

# មាតិកា



១. និយមន័យនិងប្រព័ន្ធកសិរុក្ខកម្ម

២. ការអនុវត្តន៍កសិរុក្ខកម្មនៅតំបន់ត្រូពិច

៣. សារៈសំខាន់និងជំហាននៃការបង្កើតកសិរុក្ខកម្ម

៤. ការចែករំលែកបទពិសោធន៍នៃការគ្រប់គ្រងកសិរុក្ខកម្ម

៥. សំណួរ& ចម្លើយ



# ១. និយមន័យកសិរុក្ខកម្ម

**What is Agroforestry ?**

អ្វីទៅជាកសិរុក្ខកម្ម ?

- 1. **កសិរុក្ខកម្ម** សំដៅលើចេតនាក្នុងការរួមបញ្ចូលដើមឈើទៅក្នុងប្រព័ន្ធដំណាំកសិកម្មនិងការចិញ្ចឹមសត្វ ដើម្បីបង្កើតជាផលចំណេញដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម។កសិរុក្ខកម្មត្រូវបានចាត់ទុកជាបែបនៃការប្រើប្រាស់ដីយ៉ាងសមស្រប ... គា... និងភាពធន់ទប់នៃបរិស្ថានធម្មជាតិ(ASEAN,2018)។







**2.កសិរុក្ខកម្ម**
គឺជាប្រព័ន្ធនៃការប្រើប្រាស់ដី
ដែលមានដាំដើមឈើ ដំណាំ
មនុស្ស សត្វ
នៅលើ
ផ្ទៃដីតែមួយក្នុងគោលបំណងទទួលប
ដោយ
ស្ថិតនៅលើគោលការណ៍និរន្តរភាព
(គឺការ
ប្រើប្រាស់ធនធានដែលធានានូវភាពស ... មនុ

១.




**កសិរុក្ខកម្ម** ជាប្រព័ន្ធប្រើប្រាស់ដីធ្លីតាមបែបបុរាណនិងសម័យ ដែលដើមឈើត្រូវបានគ្រប់គ្រងរួមគ្នាជាមួយដំណាំនិង/ឬប្រព័ន្ធផលិតកម្មសត្វនៅក្នុងការរៀបចំធ្វើកសិកម្ម។កសិកម្មជាប្រព័ន្ធគ្រប់គ្រងធនធានធម្មជាតិមានភាពប្រែប្រួលដោយផ្អែកលើមូលដ្ឋានអេកូឡូស៊ី
ជាប្រព័ន្ធគ្រប់គ្រងធម្មជាតិដែលមានភាពចម្រុះនិងធានានូវផលិតភាព ដើម្បីបង្កើនអត្ថប្រយោជន៍សង្គមសេដ្ឋកិច្ច និងបរិស្ថានសម្រាប់អ្នកប្រើប្រាស់ដីនៅគ្រប់លំដាប់ (FAO )។




**3.កសិរុក្ខកម្ម**
គឺជាការ
ដាំកូនឈើនិងដំណាំនៅលើដីកសិដ្ឋាននៅជុំវិញផ្ទ
ដីដែលកំពុង
ប្រើប្រាស់ឬដីចម្ការដែលនៅទំនេរ។កសិរុក្ខកម្មអាច ... នូវការប្រើប្រ
ដើម្បីទាញយកផលពីការ
ដាំដុះកូនឈើនិងដំណាំរួមផ្សំផ្សេងៗ
ក្នុងកម្រិតខ្ពស់គួរជាទីគាប់ចិត្ត
(វិទ្យាស្ថានស្រាវជ្រាវនិងបណ្តុះបណ្តាល
២០១៨)។



## និយមន័យរួម កសិរុក្ខកម្ម

គឺជាការប្រើប្រាស់ដីរួមគ្នារវាងការអនុវត្ត ... ាមួយដើមឈើ ហើយដែលមានអន្តរកម្មឱ្យគ្នាទៅវិញទៅមក ដើម្បីទទួលបាននូវផលិតភាពខ្ពស់ ផលចំណេញផ្នែកបរិស្ថាន សេដ្ឋកិច្ចនិងសង្គមប្រកបដោយ និរន្តរភាព (សិក្ខាសាលាពិគ្រោះយោបល់ខែមិ

# ១. និ



# ធាតុសំខាន់នៃកសិរុក្ខកម្ម






# ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម

**1. ប្រព័ន្ធកសិរុក្ខវប្បកម្ម**
*(Agri-silvicultursl system)*



**2. ប្រព័ន្ធបសុរុក្ខវប្បកម្ម**
*(Silvi-Pastoral system)*

**3. ប្រព័ន្ធកសិបសុរុក្ខវប្បកម្ម**
*(Agri-Silvi-Pastoral System)*

**4. ប្រព័ន្ធកសិរុក្ខកម្មចម្រុះ**
*(Integrated Agroforestry System)*

## ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម(ត)

1. ប្រព័ន្ធកសិរុក្ខវប្បកម្ម
*(Agri-silvicultursl system)*

- ប្រព័ន្ធកសិរុក្ខវប្បកម្មសំដៅលើការដាំដំណាំកសិកម្ម និងដើមឈើ (ដែលដាំដុះប ញ្ចូលគ្នារវាង[illegible]ឈើតែមួយជាមួយគ្នា ហើយមុខដំណាំអាចផ្លាស់ប្តូរ ឬដាំឡើងវិញតាមកាលវេលា)។







# ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម(ត)

**2. ប្រព័ន្ធបសុរុក្ខវប្បកម្ម**
*(Silvi-Pastoral system)*

- ប្រព័ន្ធរុក្ខបសុសត្វវប្បកម្មសំដៅលើ ដើមឈើ និងការចិញ្ចឹមសត្វ (ការដាំដុះព្រៃឈើ និងការចិញ្ចឹមសត្វនៅក្នុង ឬរកចំណីក្នុងទីព្រៃនោះ)។ ប្រព័ន្ធទី២នេះ ជាការចិញ្ចឹមសត្វឱ្យស៊ីស្មៅនៅក្រោមដើមឈើធំៗ ឬព្រៃឈើមានស្រាប់ក្នុងសហគមន៍ ចម្ការឈើដាំសម្រាប់យកផលឈើឬដំណាំឈើហូបផ្លែ។ ប្រភេទសត្វចិញ្ចឹមមានដូចជា គោ ក្របី ពពែ ចៀម ជាដើម។





## ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម(ត)

### 3. ប្រព័ន្ធកសិបសុរុក្ខវប្បកម្ម
*(Agri-Silvi-Pastoral System)*

- ប្រព័ន្ធកសិរុក្ខបសុសត្វវប្បកម្មសំដៅលើ ការដាំដំណាំកសិកម្ម ដើមឈើ និងការចិញ្ចឹមសត្វ (ការដាំដុះបញ្ចូលគ្នារវាងដំណាំកសិកម្ម ព្រៃឈើ កូនឈើ/ដើមឈើ និង ការចិញ្ចឹមសត្វនៅលើផ្ទៃដីតែមួយជាបន្តបន្ទាប់)។ ប្រព័ន្ធប្រភេទនេះអាចបំលែងជាប្រព័ន្ធរុក្ខបសុសត្វវប្បកម្មដែលមានវត្តមានតែដើមឈើ និងសត្វចិញ្ចឹម។



+



+



# ចំណាត់ថ្នាក់នៃប្រព័ន្ធកសិរុក្ខកម្ម(ត)

**4. ប្រព័ន្ធកសិរុក្ខកម្មចម្រុះ**
*(Integrated Agroforestry System)*

- ប្រព័ន្ធកសិរុក្ខកម្មចម្រុះសំដៅលើការអនុវត្តកសិរុក្ខកម្ម បសុវប្បកម្ម និងវារីវប្បកម្ម (ការដាក់បញ្ចូលគ្នារវាងដំណាំកសិកម្ម ដើមឈើ បសុសត្វ និងវារីវប្បកម្ម) រួមមានការដាំដំណាំកសិកម្មជាមួយដើមឈើដាំ ឬឈើមានស្រាប់ដោយមានការចិញ្ចឹមសត្វ (គោ ក្របី ពពែ...) និងការចិញ្ចឹមត្រី នៅក្នុងសហគមន៍ព្រៃឈើ។






# ពូជដំណាំ ពូជដើមឈើ ពូជសត្វ និងពូជត្រីដែលបានអនុញ្ញាតឱ្យដាំនៅក្នុងកសិរុក្ខកម្ម

- ដំណាំរយៈពេលខ្លី (រមៀត រំដេង ខ្ញី ត្រាវ សណ្ដែកដី ដំឡូងផ្វា សណ្ដែកគួរ ត្រសក់ ពោត...) និងដំណាំរយៈពេលមធ្យម (ដំឡូងដៃខ្លា ម្នាស់ អំពៅ ស្លឹកគ្រៃ...)
- រុក្ខវប្បកម្ម សំដៅលើការដាំដើមឈើ ឬដាំជាចម្ការដើមឈើ  ពូជឈើដែលមានតម្លៃសេដ្ឋកិច្ច និងបរិស្ថាន មានដូចជា គ្រញូង ធ្នង់ បេង នាងនួន ខ្វាវ ឬឈើសំណង់មាន ឈើទាល ផ្ចឹក ត្រាច ខ្លុង ត្បែង ជាដើម តាមតម្រូវការប្រើប្រាស់ ឬតម្រូវតាមតំបន់អេកូឡូស៊ី។
- វារីវប្បកម្ម (ការចិញ្ចឹមត្រី) នៅក្នុងសហគមន៍ព្រៃឈើត្រូវជ្រើសរើសពូជត្រីដែលមិនមានហានិភ័យដល់បរិស្ថាន។ វារីវប្បកម្មអាចធ្វើឡើងក្នុងស្រះទឹកសហគមន៍ ដែលស្រះទឹកនេះអាចរក្សាទឹកសម្រាប់គោផឹកនៅពេលរដូវប្រាំងខ្វះទឹក។
- ការចិញ្ចឹមសត្វមានដូចជា គោ ក្របី ពពែ ចៀម មាន់ ទា...។

# ២.ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូព្រិច

## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច

❑ **ការធ្វើឱ្យប្រសើរឡើងលើដីបម្រុងទុក** ( Improved fallows )

- អនុវត្តលើដី ដែលស្ថិតនៅក្នុងរយៈពេលបម្រុងទុក (Fallow) ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងគុណភាពដី ពន្លឿនការដុះលូតលាស់ឡើងវិញនូវរុក្ខជាតិដុះថ្មី ការទប់ទល់ស្មៅចង្រៃ និងការបង្កើនជីវៈចម្រុះ

…




## ២. ការអនុវត្តកសិរុក្ខកម្មនៅតំ

❑ **តុងយ៉ា** ( Taungya )

- តុងយ៉ា(Taungya) ជាពាក្យមកពីភាសាភូមា តុង (Taung) មានន័យថាភ្នំ (Hill) និង យ៉ា(Ya) មាន ន័យថាការដាំដុះ (Cultication) ពោលគឺសំដៅលើការអនុវត្តន៍ការដាំដុះដំណាំកសិរុក្ខកម្មជាមួយឈើដាំ ក្នុងអំឡុងពេ ២ឆ្នាំ ទៅ ៣ឆ្នាំ ដំបូង នៃការស្តារតាមតំបន់ជម្រា
- ការអនុវត្ត តុងយ៉ា(Taungya) ភាគច្រើនគេប្រើពូជឈើ មួយចំនួនដូចជា៖ ដើមម៉ៃសាក់ (Tectona grandis) ដើមប្រេងខ្យល់ (Eucalypyus camaldulensis) Gmeline arborea (Shorea robusta), Terminalia superba, (Pinus spp) St Cupressus spp (Lamprecht 1989, Mac Dicken 1990)




## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច ( ត )

❑ **ការដាំដំណាំជាជួរចន្លោះឆ្លាស់** ( Alley Cropping )

- ការដាំដំណាំតាមលក្ខណៈងាយៗនៅចន្លោះរង (Hedgerow) នៃដើមឈើ និងចុល្លព្រឹក្សា ៃ ភាគច្រើនជាប្រភេទដើមឈើលេគុលមីនី (leguminous)
- ដើមឈើត្រូវកាត់តម្រឹមយូរៗម្តង ដើម្បីការពារកុំឱ្យមានម្លប់ទៅគ្របលើដំណាំដែលស្ថិតក្នុង ជួរចន្លោះក្បែរៗនោះ។




## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច ( ត )




❑ **គេហ៍សួន** Home Garden

គេប្រើប្រាស់យ៉ាងទូលាយ ដើម្បីសម្គាល់នូវការអនុវត្តន៍ ផ្សេងគ្នានៃការដាំដើមឈើហូបផ្លែ និងសួនបន្លែដុះវិញលំនៅស្ថានដែលមានលក្ខណៈជាប្រព័ន្ធចំការឈើច្រើនស្រទាប់។

# ២.ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច(ត)

## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច ( ត )





❑ **ចំការដំណាំចម្រុះ** (Plantation Crop combination)

- ការដាំផុះចំការដំណាំចម្រុះច្រើនប្រភេទ នៅក្នុងទីតាំងតែមួយ ដោយមានដំណាំរយៈខ្លី និងវែងចម្រុះគ្នា ដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ
- ការអនុវត្ត ភាគច្រើនផ្តោតសំខាន់លើប្រភេទដំណាំមានតម្លៃខ្ពស់ ដូចជា ដំណាំដូងប្រេង កៅស៊ូ ដូង កាហ្វេ កាការ៉ូ តែ ស្វាយចន្ទី និងម្រេច។

## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច ( ត )

❑ **សួនដើមឈើច្រើនស្រទាប់** (Multistorey tree garden)

- សំដៅលើការដាំចម្រុះជាស្រទាប់ ដូចជា ស្រទាប់ដើមឈើ និងស្រទាប់ដំណាំផ្នែកខាងក្រោម។
- សួនដើមឈើច្រើនស្រទាប់នេះមានលក្ខណៈខុសពីគេហ៍សួន ដែលព័ទ្ធជុំវិញបរិវេណផ្ទះរៀងៗខ្លួន ហើយជាទូទៅ ប្រព័ន្ធនេះនៅឆ្ងាយពីផ្ទះ ភាគច្រើនស្ថិតនៅលើដីសហគម ន៍ដែលព័ទ្ធជុំវិញដោយភូមិករ។





## ២. ការអនុវត្តកសិរុក្ខកម្មនៅតំបន់ត្រូពិច ( ត )

❑ **របាំងការពារខ្យល់ និងទីជម្រក**

- សំដៅលើការដាំដើមឈើជុំវិញចម្ការដំណាំ ឬជារបង ដើម្បីប្រើប្រាស់របាំងខ្យល់ ការពារដំណាំ ប្រភពទឹក និងភូមិករ...
- ការដាំអាចជាជួរច្រើនស្រទាប់ អាចជារបងជុំវិញ....





# ៣.សារៈប្រយោជន៍នៃការបង្កើតកសិរុក្ខកម្ម

- បង្កើតគម្របបៃតង គម្របព្រៃឈើ ទប់ស្កាត់ការហូរច្រោះដី
- ចូលរួមទប់ស្កាត់ការប្រែប្រួលអាកាសធាតុ
- .ផលិតស្បៀងអាហារសុខសុវត្ថភាពគ្រប់គ្រាន់សម្រាប់មនុស្ស សត្វ
- ជួយឱ្យដំណើរការគ្រងគ្រងព្រៃឈើមាននិរន្តរភាព
- សត្វព្រៃ សត្វកម្រ  សត្វស្លាប និងអនុផលព្រៃឈើកើនឡើង
- ធ្វើឱ្យប្រាក់ចំណូលរបស់សហគមន៍និងសេដ្ឋកិច្ចជាតិរីកចម្រើន។
- បង្កើតតំបន់ទេសចរអេកូទេសចរធម្មជាតិ





## 2. ជួយពង្រឹងទំនាក់ទំនងប្រព័ន្ធកសិអេកូឡូស៊ី



# ជំហាននៃការបង្កើតកសិរុក្ខកម្មមាន៨ជំហាន

8th ការត្រួតពិនិត្យនិងវាយតម្លៃ

7th ការប្រមូលផលនិងការបែងចែកផលប្រយោជន៍

6th ការថែទាំនិងប្រតិបត្តិការងារកសិរុក្ខកម្ម

5th ការរៀបចំផែនការសម្រាប់ការដាំដុះ និងអនុវត្តន៍

4th ការបណ្ដុះបណ្ដាលបច្ចេកទេសកសិរុក្ខកម្

3rd រចនាសម្ព័ន្ធក្នុងការអនុវត្តកសិរុក្ខកម្ម

2nd ការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ

1st កំណត់ទីតាំងកសិរុក្ខកម្ម និងការផ្សព្វផ្សាយ

# ការកំណត់ទីតាំងកសិរុក្ខកម្ម

- ការកំណត់ទីតាំងនិងការកំណត់ព្រំប្រទល់ដោយមាននិយាមការ ដើម្បីផលិតជាផែនទីតំបន់កសិរុក្ខកម្ម។ខាងក្រោមនេះជារូបផែនទី ជាឧទាហរណ៍ក្នុងការបង្កើតជាផែនទីទីតាំងអនុវត្តកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើឆែបលិច។









# រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ



# រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងកសិរុក្ខកម្ម



# អ្នកពាក់ព័ន្ធ និងតួនាទីក្នុងការចូលរួមអភិវឌ្ឍន៍កសិរុក្ខកម្ម និងផែនការស្វែងរកថវិកា

| ភាគីពាក់ព័ន្ធ | ផែនការ និងហិរញ្ញវត្ថុ |
|---|---|
| ១ តួនាទីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល/ជាតិ<br>២. មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ<br>៣ តួនាទីអាជ្ញាធរមូលដ្ឋាន ស្រុក ឃុំ ភូមិ<br>៤តួនាទីសហគមន៍ព្រៃឈើ និងក្រុមកសិរុក្ខកម្ម<br>៥ តួនាទីអង្គការដៃគូរពាក់ព័ន្ធ | - ការរៀបចំផែនការអនុវត្តកសិរុក្ខកម្ម ឬគម្រោងកសិរុក្ខកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- ត ម្រូវឱ្យមានវិសាលភាព និងការវិភាគស្ថានភាពដើម្បីកំណត់បញ្ហាចន្លោះប្រហោង និ<br>- ស្វែងរកអ្នកគាំទ្រថវិកា(តាមរយៈថវិការដ្ឋ) និងជាអ្នកកៀរគរថវិកាពីស្ថាប័នអង្គការដៃគូ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។<br>- បញ្ចូលផែនការកសិរុក្ខកម្មក្នុងកម្មវិធីវិនិយោគឃុំ សង្កាត់។ |

# ៧. បទពិសោធន៍នៃការបង្កើតនិងគ្រប់គ្រងកសិរុក្ខកម្មនៅក្នុងសហគមន៍ព្រៃឈើ

| សកម្មភាព | លទ្ធផល | រូបភាព |
|---|---|---|
| បច្ចុប្បន្នកសិរុក្ខកម្មនៅក្នុងខេត្តក្រចេះមានចំនួន៥ ដែលបានបង្កើតនៅក្នុងសហគមន៍ព្រៃឈើ គឺ កសិរុក្ខកម្ម ប្រាសាទ<br>អង្គការFLO បានគ្រប់គ្រងកសិរុក្ខកម្មអូរកក់ និងគាំទ្រសកម្មភាពល្បាតសហគមន៍ព្រៃឈើទាំង៥ រួមទាំងក្រុម CF credit , Mini-Trust Fund .<br>FLO បានផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេកចិញ្ចឹមគោ បច្ចេកទេសដំណាំ បច្ចេកទេកដាំបន្លែតាមបែបធម្មជាតិ របៀបផលិតជីកំប៉ុស្ត ភាពជាអ្នកដឹកនាំ និងរបៀបសរសេររបាយការណ៍ហិរញ្ញវត្ថុ របៀបសារសៃរៀបចំសំណើរខ្នាតតូច បច្ចេកទេស | កសិរុក្ខកម្មទាំង៥ នៅក្នុងខេត្តក្រចេះ កំពុងតែមានដំណើរការគ្រប់គ្រងល្អ។<br>គណៈកម្មការនិងសមាជិកមានចំណេះដឹងផ្នែកបច្ចេកទេសដាំដុះបន្លែធម្មជាតិ របៀបធ្វើជីកំប៉ុស្តិ៍ បច្ចេកទេសចិញ្ចឹមគោ ល្អគ្រប់គ្រងហិរញ្ញវត្ថុ [illegible] បានយល់ដឹងច្បាស់ពីសិទ្ធិនិងតួនាទីរបស់បុរសនិង ស្ត្រី មានជំនាញភាពជាអ្នកដឹកនាំនិងគ្រប់គ្រងក្រុម ។<br>ព្រៃឈើ សត្វព្រៃ សត្វស្លាប ឃ្មុំព្រៃ សត្វកម្រជិតផុតពូជ មានចំនួនកើនឡើងវិញច្រើន ។<br>អនុផលព្រៃឈើមានការកើនឡើង ដូចជា ផ្សិត ផ្តៅ ទឹកឃ្មុំព្រៃធម្មជាតិ ......ដែលបានចូលរួមលើកកម្ពស់ជីវិភាពសហគមន៍នៅតាមទីកន្លែងដាច់ស្រយាល ពិសេសជនជាតិដើមភាគតិច បានល្អប្រសើរ។<br>បានចូលរួមទប់ស្កាត់ បទល្មើស កាប់ព្រៃឈើ កាប់ព្រៃយកដី បរបាញ់សត្វ។<br>កសិរុក្ខកម្មជាកន្លែងផ្សព្វផ្សាយបច្ចេកកសិកម្មបែបអភិរក្សទៅដល់សហគមន៍ដដៃ និងក្រុមយុវជន ជាយន្តការយ៉ាងសំខាន់ ដើម្បីឱ្យសហគមន៍មានភាពជាម្ចាស់នាពេលអនាគត។<br>កសិរុក្ខកម្មនិងសហគមន៍ព្រៃឈើទាំង៥នៅក្នុងខេត្តក្រចេះ នាពេលអនាគតនឹងអាចក្លាយទៅជាតំបន់អេកូទេសចរណ៍ធម្មជាតិបាន ដែលជាប្រភពមួយដ៏សំខាន់ក្នុងការបង្កើនប្រាក់ចំណូលរបស់សហគមន៍មូលដ្ឋាននិង ជួយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិឱ្យមានភាពរីកចម្រើនប្រកបដោយចីរភាពផងដែរ។ |  |








# THANK YOU

FLO - Forests and Livelihoods Organization

